# Forensic patients

About your rights

# អ្នកជំងឺនីតិក្រម

អំពីសិទ្ធិរបស់លោកអ្នក

Cambodian

## សេចក្ដីសង្ខេប

នៅពេលដែលលោកអ្នកជាអ្នកជំងឺផ្នែកនីតិក្រម  លោកអ្នកៈ

- នឹងមានផែនការព្យាបាលមួយ  ហើយលោកអ្នកអាចចូលរួមនៅក្នុងការធ្វើផែនការរបស់លោកអ្នកដែរ
- មានសិទ្ធិទទួលយកនូវមតិយោបល់ទីពីរពីពេទ្យឯកទេសជំងឺវិកលចរិត ស្ដីអំពីការព្យាបាលរបស់លោកអ្នក
- មានសិទ្ធិសុំដំបូន្មានផ្លូវច្បាប់  និងសុំមេធាវីម្នាក់សំរាប់តំណាងលោកអ្នក
- អាចនិយាយអំពីបញ្ហានេះជាមួយមិត្តភក្ដិ ឬសមាជិកគ្រួសារ  ដែលតំណាងឱ្យលោកអ្នក
- អាចធ្វើការតវ៉ាអំពីការព្យាបាលរបស់លោកអ្នក
- មានសិទ្ធិនៅក្រោម*លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ។ (Charter of Human Rights and Responsibilities).*

លោកអ្នកអាចសួរយោបល់ពីសមាជិកនៃក្រុមព្យាបាល មិត្តភក្ដិ សមាជិក គ្រួសារ មេធាវី អ្នកគាំទ្រ ឬភ្ញៀវសួរសុខទុក្ខមកពីសហគមន៍  ដើម្បីជួយលោកអ្នកក្នុងការធ្វើកិច្ចការទាំងនេះ ឬក៏លោកអ្នកទាក់ទងអង្គការណាមួយ  ដែលមានរាយឈ្មោះនៅខាងចុងក្រោយបង្អស់នៃកូនសៀវភៅនេះ  ។

### អំពីសិទ្ធិរបស់លោកអ្នក

កូនសៀវភៅនេះផ្ដល់ជូនព័ត៌មានស្ដីអំពីភាពជាអ្នកជំងឺផ្នែកនីតិក្រម  និងសិទ្ធិតាមផ្លូវច្បាប់របស់លោកអ្នក ព្រមទាំងការមានសិទ្ធិទទួលមួយចំនួនរបស់អ្នកជំងឺផ្នែកនីតិក្រម  *ក្រោមច្បាប់សុខភាពផ្លូវចិត្តដែលបង្កើតនៅក្នុងឆ្នាំ១៩៨៦* ។

កូនសៀវភៅនេះក៏ផ្ដល់ជូនព័ត៌មានស្ដីអំពីសិទ្ធិតាមផ្លូវច្បាប់  និងការមានសិទ្ធិទទួលមួយចំនួនរបស់អ្នកជំងឺផ្នែកនីតិក្រមខ្លះ  នៅក្រោមច្បាប់*ព្រហ្មទណ្ឌ  (ភាព  និងភាពអន់ថយនៃសុខភាពផ្លូវចិត្តដើម្បីធ្វើការកាត់ទោស)* ដែលបង្កើតនៅក្នុងឆ្នាំ  ១៩៩៧  និងក្រោមច្បាប់*ព្រហ្មទណ្ឌដែលបង្កើតឡើងនៅក្នុងឆ្នាំ  ១៩១៤*  ដោយរដ្ឋាភិបាលសហព័ន្ធ ។

សមាជិកនៃក្រុមអ្នកព្យាបាលលោកអ្នកនឹងនិយាយជាមួយលោកអ្នក  អំពីព័ត៌មាននេះ  ហើយនឹងឆ្លើយរាល់សំណួររបស់លោកអ្នក   ។ ព័ត៌មាននេះនឹងត្រូវបានពន្យល់ជាភាសាមួយ  ឬតាមវិធីណាមួយ  ដែលលោកអ្នកអាចយល់បាន  ។  កូនសៀវភៅនេះក៏ត្រូវបានបកប្រែជាភាសាមួយចំនួនផងដែរ  ។ លោកអ្នកអាចសុំកូនសៀវភៅនេះពីសមាជិកណាម្នាក់នៃក្រុមព្យាបាល ប្រសិនបើកូនសៀវភៅនេះមានសរសេរជាភាសា  ដែលលោកអ្នកចង់បាន   ។

លោកអ្នកអាចទទួលបានឯកសារចំលងនៃកូនសៀវភៅនេះជាភាសាដទៃទៀត  តាមវ៉ិបសាយៈ www.health.vic.gov.au/mentalhealth.

ឯកសារចំលងនៃច្បាប់សុខភាពផ្លូវចិត្ត  និងព្រហ្មទណ្ឌ (ពិការភាព និងភាពអន់ថយ នៃសុខភាពផ្លូវចិត្តដើម្បីធ្វើការកាត់ទោស)  មានជូនលោកអ្នកនៅតាមអង្គការថែរក្សាសុខភាពផ្លូវចិត្ត   ។

## មាតិកា


| | |
|---|---|
| អ្នកជំងឺនីតិក្រម | 2 |
| ការព្យាបាល | 2 |
| ការសំរាកពីការព្យាបាល | 3 |
| ការចាកចេញពីសេវាកម្មថែរក្សាសុខភាពផ្លូវចិត្តដើម្បីទៅរស់នៅក្នុងសហគមន៍ | 7 |
| បណ្ដឹង | 8 |
| ការទាក់ទងសំខាន់ៗ | 9 |



A Victorian Government initiative

State Government Victoria

ប្រសិននៅពេលណាដែលលោកអ្នកមានសំនួរអំពីព័ត៌មាននេះ ឬសិទ្ធិរបស់លោកអ្នក សូមលោកអ្នកធ្វើការសាកសួរនរណាម្នាក់ដើម្បីឱ្យគេពន្យល់អ្នក ។ លោកអ្នកអាចសួរសមាជិកនៃក្រុមអ្នកព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី អ្នកគាំទ្រ ឬភ្ញៀវសួរសុខទុក្ខមកពីសហគមន៍ ។

## *លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ*

*ច្បាប់លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវរដ្ឋវិចតូរីយ៉ា ឆ្នាំ 2006* ស្វែងរកការលើកកំពស់និងកិច្ចការពារសិទ្ធិមនុស្សជាក់លាក់។ លក្ខន្តិកៈនេះចែងអំពីសិទ្ធិដែលត្រូវការពារ និងតម្រូវឲ្យសេវាសុខភាពផ្លូវចិត្តបំពេញការងារឲ្យសមស្របនឹងសិទ្ធិទាំងនេះ។

លក្ខន្តិកៈនេះក៏បញ្ជាក់ផងដែរនូវពេលនិងរបៀបដែលច្បាប់រឹតត្បិតសិទ្ធិទាំងឡាយ។ ឧទាហរណ៍៖ នៅក្រោមច្បាប់សុខភាពផ្លូវចិត្ត គេអាចឃាត់ខ្លួនលោកអ្នកឲ្យនៅក្នុងសេវាសុខភាពផ្លូវចិត្ត បើវាជាការចាំបាច់ដើម្បីការពារសុខភាពលោកអ្នកឬសុវត្ថិភាពរបស់អ្នកដទៃ។ ប៉ុន្តែការរឹតត្បិតណាមួយលើសេរីភាពលោកអ្នក និងការជ្រៀតជ្រែកណាមួយទៅនឹងសិទ្ធិ ភាពផ្ទាល់ខ្លួន កិត្តិយស និងការគោរពខ្លួនឯងរបស់លោកអ្នក ត្រូវបានធ្វើទៅតាមកំរិតទាបបំផុតដែលជាការចាំបាច់នៅក្នុងកាលៈទេសៈទាំងពួង។

បើលោកអ្នកមានសំណួរណាមួយអំពីលក្ខន្តិកៈនេះ ឬថាតើលក្ខន្តិកៈនេះប្រហែលជាមានផលប៉ះពាល់យ៉ាងណាលើការព្យាបាលលោកអ្នក សូមទាក់ទងអង្គការមួយក្នុងចំណោមអង្គការទាំងឡាយដែលមានរាយឈ្មោះនៅខាងចុងបញ្ចប់នៃកូនសៀវភៅនេះ។

## អ្នកជំងឺនីតិក្រម

លោកអ្នកត្រូវបានបញ្ជូនទៅកាន់សេវាកម្មសុខភាពផ្លូវចិត្ត ក្នុងឋានៈជាអ្នកជំងឺផ្នែកនីតិក្រមម្នាក់ ដើម្បីឱ្យលោកអ្នកអាចទទួលបានការព្យាបាលជំងឺផ្លូវចិត្ត ។

លោកអ្នកត្រូវបានបញ្ជូនទៅព្យាបាលតាមមធ្យោបាយមួយក្នុងចំណោមមធ្យោបាយច្រើនយ៉ាង ។ សមាជិកម្នាក់នៃក្រុមព្យាបាលនឹងប្រាប់លោក អ្នកនូវមធ្យោបាយដែលត្រូវនឹងរូបលោកអ្នក ព្រមទាំងគូសក្នុង ប្រអប់ដែលត្រឹមត្រូវ ។

អ្នកជំងឺផ្នែកនីតិក្រមភាគច្រើនត្រូវបានបញ្ជូនព្យាបាលតាមមធ្យោបាយៈ

- ☐ **បទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក** តុលាការបាន ដាក់លោកអ្នកចូលទៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុកមួយ ។ បទបញ្ជានេះគ្មានកាលកំណត់ពេលទេ ប៉ុន្តែវានឹងផុតកំណត់នៅខណៈដែលតុលាការចេញសេចក្តីសំរេចចិត្ត ។

អ្នកជំងឺផ្នែកនីតិក្រមខ្លះទៀតត្រូវបានបញ្ជូនព្យាបាលតាមមធ្យោបាយៈ

- ☐ **បទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក** លោកអ្នកត្រូវបានបញ្ជូនព្យាបាលក្នុងនាមជាអ្នកជំងឺនីតិក្រម ពីព្រោះតែលោកអ្នកពុំបានអនុវត្តតាមបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក ហើយសុវត្ថិភាពរបស់លោកអ្នក ឬសុវត្ថិភាពរបស់អ្នកដទៃឋិតនៅក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬលោកអ្នកបានធ្វើដំណើរចាកចេញពីរដ្ឋវិចតូរីយ៉ាដោយគ្មានការអនុញ្ញាត និងត្រូវបានគេចាប់ខ្លួនព្រមទាំងបញ្ជូនទៅកាន់សេវាកម្មព្យាបាលជំងឺផ្លូវចិត្តវិញ ។

- ☐ **បទបញ្ជាមួយរបស់រដ្ឋាភិបាលសហព័ន្ធចំពោះអ្នកជំងឺនីតិក្រម** តុលាការចេញបទបញ្ជាមួយដល់លោកអ្នកក្រោមច្បាប់ព្រហ្មទណ្ឌនៃរដ្ឋាភិបាលសហព័ន្ធ សំរាប់រយៈពេលដែលមានបញ្ជាក់នៅក្នុងបទបញ្ជានោះ ។

## ការព្យាបាល

ពេទ្យឯកទេសជំងឺវិកលចរិតនឹងរៀបចំផែនការព្យាបាលមួយដែលគាត់តែងឡើង ដើម្បីឆ្លើយតបតំរូវការជាក់លាក់របស់លោកអ្នក ។ លោកអ្នកអាចចូលរួមនៅក្នុងការធ្វើផែនការព្យាបាលរបស់លោកអ្នកបាន ហើយពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកនឹងពិចារណាពីការចូលចិត្ត និងការបារម្ភរបស់លោកអ្នក ។ ពេទ្យឯកទេសជំងឺវិកលចរិតនឹងគិតពិចារណាផងដែរអំពីការចង់បានរបស់អាណាព្យាបាល សមាជិកគ្រួសារ ឬអ្នកថែរក្សាលោកអ្នកដោយផ្ទាល់ដែលមានការទាក់ទិនដល់ការផ្តល់ការថែរក្សាជាប់លាប់ដល់លោកអ្នក (លើកលែងតែលោកអ្នកបដិសេធ) និងពិចារណាពីការព្យាបាលផ្សេងទៀតដែលមានអត្ថប្រយោជន៍ ព្រមទាំងគ្រោះថ្នាក់គួរឱ្យបារម្ភទាំងឡាយដែលអាចមានដោយសារការព្យាបាលនេះ ។

ប្រសិនបើពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកជឿជាក់លើការព្យាបាលជំងឺវិកលចរិតចាំបាច់ណាមួយ នោះការព្យាបាលនេះអាចត្រូវបានផ្តល់ជូនលោកអ្នក បើទោះបីជាលោកអ្នកបដិសេធក្តី ។ ប្រសិនបើករណីនេះកើតមានឡើង នោះពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកនឹងពន្យល់លោកអ្នកថា ហេតុអ្វីការព្យាបាល នេះជាការចាំបាច់ ។ ពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នក ឬសមាជិកផ្សេងទៀតនៃក្រុមព្យាបាលនឹងពិភាក្សាជាមួយលោកអ្នក អំពីផែនការព្យាបាលរបស់លោកអ្នក ព្រមទាំងជូនលោកអ្នកនូវច្បាប់ចំលងនៃកិច្ចពិភាក្សានេះ ។

ពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នក និងសមាជិកឯទៀត នៃក្រុមព្យាបាលនឹងពិភាក្សាជាទៀងទាត់ជាមួយលោកអ្នក អំពីការវិនិច្ឆ័យជំងឺ ថ្នាំព្យាបាល វិធីសាស្ត្រព្យាបាល ការព្យាបាលផ្សេងទៀត និងសេវាកម្មបំរើឯទៀតដែលអាចមានសំរាប់លោកអ្នក ។ ពួកគេទាំងនោះនឹងធ្វើការពិនិត្យឡើងវិញ ព្រមទាំងកែសំរួលផែនការព្យាបាលលោកអ្នកយ៉ាងទៀងទាត់ ។ លោកអ្នកអាចមានមិត្តភក្តិ ឬតំណាងតាមផ្លូវច្បាប់នៅជាមួយលោកអ្នកក្នុងខណៈលោកអ្នកកំពុងពិភាក្សាអំពីការព្យាបាលរបស់លោកអ្នកជាមួយពេទ្យឯកទេសជំងឺវិកលចរិត ។

សមាជិកគ្រួសារ និងអ្នកថែទាំលោកអ្នកអាចផ្តល់ការគាំទ្រដ៏ថ្លៃថ្លា និងការថែទាំដល់លោកអ្នក ក្នុងខណៈដែលលោកអ្នកកំពុងតែទទួលការព្យាបាលជំងឺរបស់លោកអ្នក ។ ជាទូទៅ គេជូនព័ត៌មានអំពីការព្យាបាលនេះដល់សមាជិកគ្រួសារ និងអ្នកថែទាំលោកអ្នកបានលុះត្រាតែមានការយល់ព្រមពីលោកអ្នក ។ ប៉ុន្តែទោះជាដូច្នេះក្តី ប្រសិនបើសមាជិកគ្រួសារ អាណាព្យាបាល និងអ្នកថែទាំលោកអ្នកផ្ទាល់ត្រូវការព័ត៌មានអំពីការព្យាបាលនេះដើម្បីធ្វើការថែទាំលោកអ្នក ហើយបើទោះជាលោកអ្នកពុំយល់ព្រមក្តី ក៏សមាជិកក្រុមអ្នកព្យាបាលនៅតែអាចផ្តល់ព័ត៌មានជូនពួកគេដែរ ។

### មតិយោបល់ទីពីរ

វាជាសិទ្ធិរបស់លោកអ្នក ដើម្បីរកមតិយោបល់ទីពីរអំពីជំងឺវិកលចរិត និងការព្យាបាលរបស់លោកអ្នក ។ អ្នកសំរបសំរួលករណីលោកអ្នក ឬពេទ្យព្យាបាលជំងឺវិកលចរិតរបស់លោកអ្នករៀបចំកិច្ចការនេះ នៅក្នុងមន្ទីរពេទ្យក៏បាន ឬក៏ពួកគេជួយលោកអ្នកដើម្បីជ្រើសរើសពេទ្យឯកទេសជំងឺវិកលចរិតដែលលោកអ្នកចង់បាន ។ បើសិនជាលោកអ្នកជ្រើសរើសពេទ្យឯកទេសជំងឺវិកលចរិតឯកជន លោកអ្នកប្រហែលជាត្រូវបង់ប្រាក់ថ្លៃឈ្នួលសេវាកម្មនេះ ។

លោកអ្នកអាចពិភាក្សាអំពីមតិយោបល់ទីពីរនេះជាមួយនឹងពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នក ប៉ុន្តែមានតែពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកទេ ដែលទទួលខុសត្រូវចំពោះការធ្វើសេចក្តីសំរេចចិត្តចុងក្រោយ អំពីការព្យាបាលជូនលោកអ្នក ។

## ការមានសិទ្ធិទទួលព័ត៌មាន

វាជាសិទ្ធិរបស់លោកអ្នកក្រោមច្បាប់សេរីភាពនៃការទទួលព័ត៌មាន ដើម្បីដាក់ពាក្យសុំយកព័ត៌មានជាឯកសារ ស្តីអំពីព័ត៌មានផ្ទាល់ខ្លួន ដែលមន្ទីរពេទ្យសុខភាពផ្លូវចិត្តកំពុងរក្សាទុក ។ ប្រសិនបើលោកអ្នកចង់បានព័ត៌មាន លោកអ្នកអាចសុំវាពីសមាជិកនៃក្រុមព្យាបាលរបស់លោកអ្នក ឬក៏មន្ត្រីផ្នែកសិទ្ធិទទួលព័ត៌មានដែលធ្វើការនៅក្នុងមន្ទីរពេទ្យសុខភាពជំងឺផ្លូវចិត្ត ដើម្បីឱ្យគេជួយដាក់ពាក្យសុំព័ត៌មានជូនលោកអ្នក ។

អង្គការដែលអាចជួយលោកអ្នកក្នុងការដាក់ពាក្យទទួលព័ត៌មាននេះ មានរាយឈ្មោះនៅផ្នែកខាងក្រោយបំផុតនៃកូនសៀវភៅនេះ ។

## ការដាក់អ្នកជំងឺដាច់ដោយឡែកតែឯង និងការបង្ខាំងទុក

### ការដាក់អ្នកជំងឺដាច់ដោយឡែកតែឯង

ការដាក់អ្នកជំងឺដាច់ដោយឡែកតែឯង គឺនៅពេលណាដែលជនម្នាក់ត្រូវបានគេរក្សាទុកនៅក្នុងបន្ទប់មួយតែម្នាក់ឯង ដែលក្នុងនោះរាល់ទ្វារនិងបង្អួចត្រូវគេចាក់សោជាប់ពីខាងក្រៅ ។ ករណីនេះកើតមានឡើង នៅពេលណាចាំបាច់ដើម្បីការពារអ្នកជំងឺ ឬអ្នកដទៃពីគ្រោះថ្នាក់ដែលកើតឡើងជាបន្ទាន់ ឬដែលបំរុងនឹងកើតមានដល់សុខភាព ឬសុវត្ថិភាពរបស់គេ ឬដើម្បីការពារគេពីការគេចខ្លួន ។ វិធីនេះត្រូវបានប្រើនៅពេលដែលវិធីផ្សេងៗទៀតដើម្បីរក្សាសុវត្ថិភាពទទួលបរាជ័យ ។

### ការបង្ខាំងទុក

ការបង្ខាំងទុកគឺជាការប្រើប្រាស់ឧបករណ៍មួយដូចជា ខ្សែឬច្រវ៉ាក់ ដើម្បីកុំឱ្យអ្នកជំងឺអាចមានសេរីភាពធ្វើសកម្មភាព ។ ការបង្ខាំងទុក នេះត្រូវបានប្រើប្រាស់ដើម្បីឱ្យអ្នកជំងឺអាចទទួលបានការព្យាបាល ដើម្បីការពារអ្នកជំងឺពីការធ្វើឱ្យរងរបួសខ្លួនឯង ឬធ្វើឱ្យរបួសដល់អ្នកដទៃ ឬដើម្បីការពារកុំឱ្យអ្នកជំងឺធ្វើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។

### ការយល់ព្រម និងការត្រួតពិនិត្យនៃការដាក់អ្នកជំងឺដាច់ដោយឡែកតែឯង និងការបង្ខាំងទុក

ការដាក់អ្នកជំងឺដាច់ដោយឡែកតែឯង និងការបង្ខាំងទុកអាចអនុញ្ញាតឱ្យធ្វើឡើងបានលុះត្រាតែមានការយល់ព្រមពីពេទ្យឯកទេសព្យាបាលជំងឺវិកលចរិតក្នុងករណីសង្គ្រោះបន្ទាន់ ឬលុះត្រាតែមានការផ្តល់ អំណាចពីគិលានុបដ្ឋាកជាន់ខ្ពស់ទទួលបន្ទុកការងារនេះ ។ វិធីនេះអាចយកមកប្រើប្រាស់បានលុះត្រាមានហេតុផលដូចបានរៀបរាប់ខាងលើ ។

ប្រសិនបើលោកអ្នកត្រូវបានដាក់នៅដាច់ដោយឡែកតែឯង ឬបង្ខាំងទុក ពេលនោះបុគ្គលិកព្យាបាលត្រូវតែផ្តល់ជូនលោកអ្នកនូវកន្លែងសំរាន្តសមរម្យ សំលៀកបំពាក់ ចំណីអាហារ និងទឹកឱ្យបានសមស្របតាមពេលវេលា ។ លោកអ្នកអាចសុំចំណីអាហារ និងទឹកពីបុគ្គលិកនៅពេលណាលោកអ្នកចង់ទទួលទាន ។ បុគ្គលិកត្រូវតែផ្តល់ការរៀបចំជូនឱ្យបានគ្រប់គ្រាន់នូវបន្ទប់អនាម័យ-បង្គន់ រួមទាំងឱកាសលាងសំអាតទៀតផង ។

យ៉ាងហោចណាស់រៀងរាល់១៥នាទីម្តង គិលានុបដ្ឋាកត្រូវតែពិនិត្យឡើងវិញនូវល័ក្ខខ័ណ្ឌសុខភាពរាងកាយ និងផ្លូវចិត្តរបស់លោកអ្នក ។ យ៉ាងហោចណាស់ ៤ម៉ោងម្តង វេជ្ជបណ្ឌិតត្រូវឆែកពិនិត្យលោកអ្នក លើកលែងតែពេទ្យជំងឺវិកលចរិតគិតថា ពុំចាំបាច់ពិនិត្យញឹកញាប់ពេកទេ ។ បើសិនលោកអ្នកត្រូវគេបង្ខាំងទុក នោះលោកអ្នកត្រូវបានគេឃ្លាំពិនិត្យជាប់រហូត ។

## ល័ក្ខខ័ណ្ឌសន្តិសុខ

នៅពេលណាលោកអ្នកស្នាក់នៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ពេលនោះពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកអាចប្រើប្រាស់ល័ក្ខខ័ណ្ឌសន្តិសុខណាមួយដែលគិតថាវាជាការចាំបាច់ ឧទាហរណ៍កំណត់ការប្រើប្រាស់ទូរស័ព្ទ ឬការបើកសំបុត្រអាន ។ ល័ក្ខខ័ណ្ឌសន្តិសុខទាំងនេះត្រូវប្រើប្រាស់ដើម្បីធានាសុខភាព ឬសុវត្ថិភាពរបស់លោកអ្នក ឬដើម្បីការពារជនដទៃទៀតនៅក្នុងទីសាធារណៈ ។

## សំបុត្រ និងការនិយាយទូរស័ព្ទ

លោកអ្នកអាចទាក់ទងមនុស្សតាមរយៈសំបុត្រ ឬទូរស័ព្ទ លើកលែងតែពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកបានដាក់ល័ក្ខខ័ណ្ឌសន្តិសុខទៅលើរូបលោកអ្នក ។

## ការបញ្ជូនទៅសេវាកម្មផ្សេងទៀត

លោកអ្នកអាចត្រូវបានគេបញ្ជូនទៅកាន់សេវាកម្មថែរក្សាជំងឺផ្លូវចិត្តផ្សេងទៀត ប្រសិនបើប្រធានឯកទេសវិកលចរិតជឿជាក់ថា លោកអ្នកនឹងទទួលបានសារប្រយោជន៍ពីការបញ្ជូនទៅកាន់សេវាកម្មផ្សេងនេះ ឬក៏ការបញ្ជូននេះជាការចាំបាច់សំរាប់ការព្យាបាលរូបលោក អ្នក ។ បើសិនជាលោកអ្នកមិនចង់ឱ្យគេបញ្ជូនទេ លោកអ្នកគួរតែនិយាយជា មួយអ្នកឯកទេសព្យាបាលវិកលចរិត ឬក៏លោកអ្នកអាចប្តឹង តវ៉ាទៅកាន់ក្រុមប្រឹក្សាសំរេចការសំរាកពីការព្យាបាលរបស់អ្នកជំងឺនីតិក្រម ។ ប្រសិនបើគេបញ្ជូនលោកអ្នកទៅសេវាកម្មផ្សេងនៅមុនការប្តឹងតវ៉ា ពេលនោះក្រុមប្រឹក្សាសំរេចការសំរាកពីការព្យាបាលរបស់អ្នកជំងឺនីតិក្រនឹងធ្វើសេចក្តីសំរេចចិត្តពីការវិលត្រលប់មកកាន់សេវាកម្មចាស់នៅក្នុងតុលាការបណ្តឹងតវ៉ា ។

### អ្នកជំងឺនីតិក្រមរបស់រដ្ឋាភិបាលសហព័ន្ធ

ប្រសិនបើលោកអ្នកជាអ្នកជំងឺនីតិក្រមរបស់រដ្ឋាភិបាលសហព័ន្ធ ពេលនោះលោកអ្នកអាចត្រូវគេបញ្ជូនទៅកាន់មន្ទីរពេទ្យផ្សេងទៀត ឬទៅកាន់មន្ទីរ

ឃុំឃាំង បើសិនជាៈ

- មានហេតុផលបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ឬសន្តិសុខ
- អគ្គរដ្ឋអាជ្ញារបស់រដ្ឋាភិបាលសហព័ន្ធចេញបញ្ជាឱ្យមានការបញ្ជូន

## របាយការណ៍ជូនតុលាការ

ប្រសិនបើលោកអ្នកថិតនៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក ឬបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក ពេលនោះរបាយការណ៍អំពីការព្យាបាល និងការរីកចំរើន ត្រូវតែធ្វើជូនតុលាការ ដែល របាយការណ៍នេះប្រើសំរាប់ចេញបទបញ្ជាមើលគ្រប់គ្រង ដែលធ្វើឡើងជារៀងរាល់១២ខែម្តងយ៉ាងហោចណាស់ ។

# ការសំរាកពីការព្យាបាល

ការសំរាកពីការព្យាបាលគឺអនុញ្ញាតិឱ្យអ្នកជំងឺនីតិក្រមចាកចេញពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តសំរាប់គោលបំណងជាច្រើន ។ ការសំរាកពីការព្យាបាលនេះតែងតែឋិតនៅក្រោមលក្ខខណ្ឌសន្តិសុខ និងពេលវេលាដែលកំណត់ ។ មានការសំរាកពីការព្យាបាលរយៈពេលខ្លីៗចំនួនបីប្រភេទៈ ការសំរាកពីការ

ព្យាបាលដោយសារករណីពិសេស ការសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល និងការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល ។ អ្នកជំងឺនៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក ក៏អាចដាក់ពាក្យសុំចាកចេញរយៈពេលយូរ ដែលគេឱ្យឈ្មោះថាការចាកចេញសំរាប់រយៈពេលវែង ។ នៅពេលណាដែលលោកអ្នកចង់ចាកចេញពីមន្ទីរពេទ្យសុខភាពផ្លូវចិត្ត លោកអ្នកគួរតែនិយាយជាមួយពេទ្យឯកទេសជំងឺរីកលចរិត ឬសមាជិកនៃអ្នកព្យាបាលជំងឺរីកលចរិតរបស់លោកអ្នក ស្តីអំពីការដាក់ពាក្យសុំសំរាកពីការព្យាបាលនេះ ។

## ការសំរាកពីការព្យាបាលដោយសារករណីពិសេស

ពេទ្យឯកទេសជំងឺរីកលចរិតអាចអនុញ្ញាតការសំរាកពីការព្យាបាលដោយសារករណីពិសេសដល់លោកអ្នក ។ ការសំរាកពីការព្យាបាលដោយសារករណីពិសេស នេះគឺសំរាប់គោលបំណងជាក់លាក់ ដូចជាការព្យាបាលដោយថ្នាំពេទ្យការឡើងតុលាការ ឬព្រឹត្តិការណ៍ពិសេស (ដូចជាការចូលរួមបុណ្យសព) ។ ការសំរាកពីការព្យាបាលសោយសារករណីពិសេសនេះមិនអាចលើសពី២៤ម៉ោង ឬ៧ថ្ងៃឡើយក្នុងករណីមានការព្យាបាលដោយប្រើថ្នាំពេទ្យ ។

លោកអ្នក ឬនរណាម្នាក់ដែលជាតំណាងលោកអ្នកអាចដាក់ពាក្យសុំការសំរាកពីការព្យាបាលនេះទៅកាន់ពេទ្យឯកទេសជំងឺរីកលចរិតរបស់លោកអ្នកដោយបញ្ជាក់អំពីកាលៈទេសៈពិសេស ដែលតំរូវឱ្យលោក អ្នកសុំការសំរាកពីការព្យាបាលសារករណីពិសេស ។ បើសិនពេទ្យឯកទេសជំងឺរីកលចរិតរបស់លោកអ្នកយល់ស្របចំពោះកាលៈទេសៈពិសេសនេះ និងសុវត្ថិភាពរបស់សាធារណជននឹងមិនឋិតនៅក្នុងគ្រោះថ្នាក់ធ្ងន់ធ្ងរ ទេនោះ ការសំរាកពីការព្យាបាលដោយសារករណីពិសេស នឹងត្រូវបានផ្តល់ជូនលោកអ្នក ។ ប្រសិនបើពេទ្យឯកទេសជំងឺរីកលចរិតរបស់លោកអ្នកបដិសេធការផ្តល់ការសំរាកពីការព្យាបាលដោយសារករណីពិសេស លោកអ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម (សូមមើលព័ត៌មានជាប់នេះ) ។

## ការសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល និងការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល

ដើម្បីទទួលបានការសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល និងការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល លោកអ្នកត្រូវតែដាក់ពាក្យសុំសំរាកពីការព្យាបាលនេះទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម(សូមមើលព័ត៌មានជាប់នេះ) ។

ការសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល អនុញ្ញាតិឱ្យអ្នកជំងឺនីតិក្រមចាកចេញពីមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ប៉ុន្តែការចាកចេញនេះមានការកំណត់ទីតាំងនៅជុំវិញមន្ទីរពេទ្យព្យាបាល ដែលឱ្យឈ្មោះថាទីតាំងជុំវិញ ។

ការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល អនុញ្ញាតឱ្យអ្នកជំងឺនីតិក្រមចាកចេញពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តហួស ទីតាំងជុំវិញមន្ទីរពេទ្យបាន ។ ជាទូទៅការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាលអនុញ្ញាតឱ្យតែក្នុងអំឡុងពេលថ្ងៃរវាងម៉ោង៦ព្រឹក ដល់ម៉ោង៩យប់ប៉ុណ្ណោះ ។ គេអាចឱ្យលើសក្រៅពីម៉ោងខាងលើ ប៉ុន្តែត្រឹមតែ៣ថ្ងៃជាអតិបរមា ក្នុងរយៈពេល៧ថ្ងៃ ។ គេអាចឱ្យការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាលនេះក្នុងអំឡុងពេលរហូតដល់៦ខែ ។ នៅចុងបញ្ចប់នៃពេល៦ខែនេះ លោកអ្នកត្រូវដាក់ពាក្យសុំការសំរាកនេះជាថ្មី ទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។

គោលបំណងនៃការសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល និងការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាលគឺដើម្បីជួយដល់ការព្យាបាល និងការស្តារឡើងវិញនូវសុខភាពរបស់អ្នជំងឺនីតិក្រម ។

## ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

ផ្នែកនេះនៃកូនសៀវភៅគឺជូនព័ត៌មានអំពីសិទ្ធិ និងការមានសិទ្ធិទទួលរបស់លោកអ្នក ដើម្បីដាក់ពាក្យសុំការសំរាកពីការព្យាបាល ឬការដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។

### តួនាទីរបស់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម គឺជាតុលាការឯករាជ្យដែលធ្វើការវិនិច្ឆ័យករណីៈ

- ពាក្យសុំសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល និងការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល
- ពាក្យបណ្តឹងពីអ្នកជំងឺនីតិក្រម ដែលទទួលការបដិសេធការសំរាកពីការព្យាបាលពីសំណាក់ពេទ្យឯកទេសជំងឺរីកលចរិត ។
- ពាក្យបណ្តឹងពីអ្នកជំងឺនីតិក្រម ដែលពុំចង់ផ្លាស់ទៅកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្តផ្សេងទៀត ។

### ការដាក់ពាក្យសុំសំរាកពីការព្យាបាលទៅកាន់ក្រុមបឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

សុំសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល ឬការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល លោកអ្នកគួរតែនិយាយជាមួយក្រុមពេទ្យព្យាបាល ។ ពួកគេនឹងអាចផ្តល់ដំបូន្មានដល់លោកអ្នក និងពិភាក្សាពីជំរើសរបស់លោកអ្នក ។ ប្រសិនបើក្រុមពេទ្យព្យាបាលរបស់លោកអ្នកជឿជាក់ថា លោកអ្នកដល់ពេលសំរាកពីការព្យាបាលហើយ ពួកគេនឹងពិនិត្យសើរើផែនការព្យាបាល និងរៀបចំផែនការសំរាកពីការព្យាបាលរបស់លោកអ្នក ។ វាជាការសំខាន់ណាស់ដែលមានក្រុមពេទ្យព្យាបាលចូលរួមធ្វើកិច្ចការនេះ ពីព្រោះក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ចង់ដឹងពីការគាំទ្ររបស់ក្រុមពេទ្យព្យាបាលចំពោះពាក្យសុំសំរាកពីការព្យាបាលរបស់លោកអ្នក និងទំនាក់ទំនងរវាងផែនការព្យាបាល និងផែនការសុំសំរាកពីការព្យាបាលរបស់លោកអ្នក ។

ដើម្បីដាក់ពាក្យសុំសំរាកពីការព្យាបាលដោយស្នាក់នៅក្នុងបរិវេណកន្លែង ព្យាបាល ឬការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាល ឬដាក់ពាក្យប្តឹងតវ៉ាចំពោះការបដិសេធការសំរាកពីការព្យាបាល សូមធ្វើការសាកសួរសមាជិកនៃក្រុមពេទ្យព្យាបាលលោកអ្នក ដើម្បីស្នើពាក្យសុំ ដែលសមស្រប បន្ទាប់មកបំពេញពាក្យសុំនេះរួចហើយស្នើសមាជិកនៃក្រុមព្យាបាល ប្រគល់ជូនក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។ បើសិនពុំមានពាក្យសុំសមស្របទេ លោកអ្នកអាចសរសេរលិខិតទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ដោយដាក់ឈ្មោះលោកអ្នក ឈ្មោះមន្ទីរពេទ្យ និងប្រភេទការសំរាកពីការព្យាបាលដែលលោកអ្នកចង់បាន ។ ពាក្យសុំ ឬលិខិតនេះគួរផ្ញើតាមប៉ុស្តិ៍ ឬទូរសារដូចខាងក្រោមៈ

Executive Officer
Forensic Leave Panel
50 Lonsdale Street, Melbourne 3000

ទូរស័ព្ទឥតគិតថ្លៃៈ 1800 222 987
ទូរសារៈ 9096 6130

ប្រសិនបើលោកអ្នកត្រូវការជំនួយ ដើម្បីបំពេញពាក្យសុំ ឬជំនួយដើម្បីអ្វីមួយ លោកអ្នកគួរតែសួរក្រុមពេទ្យព្យាបាលរបស់លោកអ្នក មិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬភ្ញៀវសាកសួរសុខទុក្ខមកពីសហគមន៍ដើម្បីឱ្យគេជួយលោកអ្នក ។

## ការរៀបចំដើម្បីចូលរួមការវិនិច្ឆ័យរបស់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម នឹងរៀបចំផ្តល់ដំណឹងស្តីពីថ្ងៃខែឆ្នាំ ពេលម៉ោង និងទីកន្លែងដែលធ្វើការវិនិច្ឆ័យពាក្យសុំរបស់លោកអ្នក ។ វាជាសិទ្ធិរបស់លោកអ្នកដើម្បីចូលរួមការវិនិច្ឆ័យ និងដើម្បីធ្វើជាតំណាងករណីរបស់ខ្លួនឯង ហើយលោកអ្នកត្រូវគេលើកទឹកចិត្តឱ្យធ្វើដូច្នេះ ។ លោកអ្នកអាចមាននរណាម្នាក់ចូលរួមជាមួយដើម្បីផ្តល់ការគាំទ្រ ឬនិយាយជំនួសលោកអ្នក ឧទាហរណ៍ អ្នកគាំទ្រ មេធាវី មិត្តភក្តិ ឬសមាជិកគ្រួសារ ។ បើសិនជាលោកអ្នកពុំអាចចូលរួមការវិនិច្ឆ័យបានទេ លោកអ្នកគួរតែជំរាបក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមនេះឱ្យបានឆាប់រហ័ស ។

មុនការវិនិច្ឆ័យសូមលោកអ្នកអានឯកសារទាំងឡាយដែលនឹងផ្តល់ជូនក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមសំរាប់ធ្វើការវិនិច្ឆ័យ (សូមអានព័ត៌មានខាងក្រោម) និងសូមធ្វើការគិតគូរនូវអ្វីដែលលោកអ្នកនឹងត្រូវនិយាយប្រាប់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។ លោកអ្នកអាចជូនព័ត៌មានជាលាយលក្ខអក្សរដល់ក្រុមការងារនេះ ។ គ្រួសារ និងមិត្តភក្តិ ឬអ្នកណាម្នាក់ ដែលលោកអ្នកគោរព អាចចង់សរសេរលិខិត ឬចូលរួមស្តាប់ការិច្ឆ័យ ដើម្បីគាំទ្រពាក្យសុំសំរាកពីការព្យាបាលរបស់លោកអ្នក ។

បើលោកអ្នកមានសេចក្តីត្រូវការពិសេស ដូចជាត្រូវការអ្នកបកប្រែភាសា លោកអ្នកគួរតែពិភាក្សាជាមួយសមាជិកម្នាក់នៃក្រុមព្យាបាល ឬទាក់ទងទៅក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។ ក្រុមនេះនឹងរៀបចំអ្នកបកប្រែភាសាជូនលោកអ្នកប្រសិនបើចាំបាច់ ។

អង្គការទាំងឡាយដែលអាចជួយលោកអ្នកពីបញ្ហាដាក់ពាក្យសុំចាកចេញពីមន្ទីរពេទ្យ គឺមានរាយឈ្មោះនៅខាងចុងបង្អស់នៃកូនសៀវភៅនេះ ។

## សិទ្ធិសុំឯកសារសំរាប់ការវិនិច្ឆ័យពាក្យសុំសំរាកពីការព្យាបាល

លោកអ្នក ឬអ្នកតំណាងលោកអ្នកនឹងទទួលបានឱកាសដើម្បីអានឯកសារណាមួយ ២៤ម៉ោងមុនឯកសារទាំងនោះត្រូវប្រគល់ជូនក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមដើម្បីធ្វើការវិនិច្ឆ័យករណីរបស់លោកអ្នក ។ ឯកសារទាំងនោះមានឯកសារវេជ្ជសាស្ត្រ របាយការណ៍ជំងឺវិកលចរិត និងការពិពណ៌នាអំពីរូបលោកអ្នក និងផែនការសំរាកពីការព្យាបាលរបស់លោកអ្នក ។ យ៉ាងណាក៏ដោយ ក៏ពេទ្យឯកទេសជំងឺវិកលចរិតរបស់លោកអ្នកអាចដាក់ពាក្យទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមដើម្បីទប់ស្កាត់មិនឱ្យលោកអ្នកឃើញឯកសារណាមួយ ឬក៏ផ្នែកណាមួយនៃឯកសារនោះ ប្រសិនបើគេជឿថាៈ

- ការឃើញឯកសារនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពរបស់លោកអ្នក ឬសុខភាព ឬសុវត្ថិភាពរបស់ជនដទៃ

  ឬ

- ឯកសារទាំងនោះមានព័ត៌មានដែលផ្តល់ក្នុងភាពលាក់ការណ៍ ឬក៏ជាព័ត៌មានផ្ទាល់ខ្លួនរបស់ជនដទៃ ។

ប្រសិនបើមានពាក្យសុំការពារមិនឱ្យលោកអ្នកឃើញឯកសារណាមួយ ឬផ្នែកណាមួយនៃឯកសារ សមាជិកនៃក្រុមព្យាបាល លោកអ្នកនឹងនិយាយប្រាប់ហើយពន្យល់លោកអ្នកអំពីដំណើរការនេះ ។ ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមនឹងធ្វើសេចក្តីសំរេចចុងក្រោយអំពីថាតើលោកអ្នកអាចមើលឯកសារទាំងមូល ឬតែមួយផ្នែកនៃឯកសារ ឬក៏មិនអាចមើលឯកសារអ្វីទាំងអស់ ។ បើសិនជាក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមធ្វើសេចក្តីសំរេចចិត្តថាមិនឱ្យលោកអ្នកមើលឯកសារណាមួយ ឬក៏ផ្នែកណាមួយនៃឯកសារ ប៉ុន្តែក្រុមនេះប្រហែលជាអនុញ្ញាតឱ្យតំណាងលោកអ្នកមើលឯកសារជំនួសលោកអ្នកបាន ។

## ការវិនិច្ឆ័យរបស់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

ការវិនិច្ឆ័យនេះនឹងប្រព្រឹត្តឡើងនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ។ សមាជិកនៃក្រុមក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមគឺមានចៅក្រម សមាជិកសហគមន៍ ប្រធានពេទ្យឯកទេសជំងឺវិកលចរិត និងវេជ្ជបណ្ឌិត ។

ការវិនិច្ឆ័យនេះធ្វើឡើងជាលក្ខណៈឯកជន និងមិនផ្លូវការ លើកលែងតែក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាល ដល់អ្នកជំងឺនីតិក្រមសំរេចចិត្តថាវាជាប្រយោជន៍ល្អបំផុតរបស់លោកអ្នក ឬរបស់សាធារណជនសំរាប់ការវិនិច្ឆ័យធ្វើឡើងក្នុងលក្ខណៈចំហរជាសាធារណៈ ។ ពុំមានច្បាប់តឹងតែងដែលក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមត្រូវអនុវត្តដូចជាតុលាការកាត់ក្តីនោះទេ ហើយក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមអាចជូនព័ត៌មានរបស់ខ្លួនតាមវិធីណាក៏បាន ឱ្យតែក្រុមប្រឹក្សានេះគិតថាសមស្រប ។ អ្នកឯកទេសជំងឺវិកលចរិត និងសមាជិកដទៃទៀតនៃក្រុមព្យាលលោកអ្នកនឹងផ្តល់ព័ត៌មានដល់ ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។ ចំពោះភាគីខាងលោកអ្នកគឺលោកអ្នក និងអ្នកគាំទ្រលោកអ្នកអាចសួរសំនួរ និងពន្យល់ពីករណីរបស់លោកអ្នក ឧទាហរណ៍ មូលហេតុនៃការជឿជាក់ថា លោកអ្នកគួរតែបានទទួលការសំរាកពីការព្យាបាល ។

## សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម

### ការផ្តល់ការសំរាកពីការព្យាបាល

ប្រសិនបើក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមពេញចិត្តថា ការសុំសំរាកនេះនឹងជួយដល់ការស្តារសុខភាពរបស់លោកអ្នក ហើយពុំនាំគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់លោកអ្នក ឬសុវត្ថិភាពរបស់សាធារណជនទេនោះ ពេលនោះក្រុមប្រឹក្សាអាចផ្តល់ការអនុញ្ញាតឱ្យលោកអ្នកសំរាកពីការព្យាបាល ។ ក្រុមប្រឹក្សានេះនឹងដាក់លក្ខខ័ណ្ឌចំពោះការសំរាកនេះ ឧទាហរណ៍ការដើរតាមយាមរូបលោកអ្នកជាប់ជានិច្ចពីសំណាក់សមាជិកនៃក្រុមព្យាបាល ។ លោកអ្នក និងអ្នកគាំទ្ររបស់លោកអ្នកនឹងបានទទួលច្បាប់ចំលងមួយស្តីពីលក្ខខ័ណ្ឌនៃការសំរាកពីការព្យាបាលនេះ ។

ការសំរាកពីការព្យាបាលអាចត្រូវបានផ្តល់ជូនសំរាប់រយៈពេល៦ខែ ។ នៅចុងបញ្ចប់នៃពេល៦ខែនេះ លោកអ្នកអាចដាក់ពាក្យសុំសំរាកពីការព្យាបាលជាថ្មីទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ។ លោកអ្នកអាចសុំនៅពេលណាក៏បានចំពោះការសំរាកពីការព្យាបាលដែលមានលក្ខខ័ណ្ឌខុសៗគ្នា ប្រសិនបើកាលៈទេសៈរបស់លោកអ្នកបានផ្លាស់ប្តូរ ឧទាហរណ៍ បើសិនជាមានកម្មវិធីថ្មីសំរាប់ស្តារអ្នកជំងឺផ្លូវចិត្ត ។

## ការបដិសេធការសុំសំរាកពីការព្យាបាល

ប្រសិនបើក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម បានបដិសេធពាក្យសុំសំរាកពីការព្យាបាល លោកអ្នកគួរតែនិយាយជាមួយអ្នកសំរបសំរួលករណីរបស់លោកអ្នក ឬសមាជិកផ្សេងទៀតនៃក្រុមព្យាបាល និងពិភាក្សាអំពីហេតុផលទាំងឡាយ ។

ពួកគេប្រហែលជាអាចជួយលោកអ្នកក្នុងការដាក់ពាក្យសុំផ្សេងទៀត ហើយដែលពាក្យសុំថ្មីនេះទំនងជាអាចទទួលបានការអនុញ្ញាត ។ នៅខណៈដែលលោកអ្នកនៅជាអ្នកជំងឺនីតិក្រមលោកអ្នកអាចដាក់ពាក្យសុំការសំរាកពីការព្យាបាលនេះទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពី ការព្យាបាលដល់អ្នកជំងឺនីតិក្រមនៅពេលណាក៏បាន ។ ពេទ្យឯកទេសរិកលចរិត និងសមាជិកនៃក្រុមព្យបាលរបស់លោកអ្នកនឹងពិនិត្យសើរើឡើងវិញផងដែរនូវការរីកចំរើនរបស់លោកអ្នក ដើម្បីឱ្យដឹងថាតើត្រូវដាក់ពាក្យសុំសំរាកពីការព្យាបាលជាថ្មីទៀតឬទេ ។

## ការសំរាកពីការព្យាបាលដោយសារមានករណីពិសេស

ប្រសិនបើលោកអ្នកបានដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ពីព្រោះតែលោកអ្នកបានទទួលការបដិសេធការសំរាកពីការព្យាបាលដោយសារមាករណីពិសេសពីសំណាក់ពេទ្យឯកទេសជំងឺរិកលចរិត ពេលនោះក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមអាចផ្តល់ការសំរាកពីព្យាបាលដោយសារមានករណីពិសេសនេះ បើសិនជាគេជឿថាមានកាលៈទេសៈពិសេស ហើយការអនុញ្ញាតនេះមិនបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់សាធារណជនទេនោះ ។

## ការបញ្ជូនទៅកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្តផ្សេងទៀត

ប្រសិនបើលោកអ្នកបានដាក់ពាក្យបណ្តឹងតវ៉ាប្រឆាំងនឹងការបញ្ជូនទៅកាន់មន្ទីរព្យាបាលផ្សេងទៀត នោះក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រមនឹងធ្វើការសំរេចចិត្តថាតើលោកអ្នកគួរតែត្រូវបានបញ្ជូនដែរឬអត់ ។ បើសិនលោកអ្នកត្រូវបានគេបញ្ជូនមុនដាក់ពាក្យប្តឹងតវ៉ា ពេលនោះក្រុមប្រឹក្សានេះនឹងធ្វើសេចក្តីសំរេចចិត្តថាតើលោកអ្នកគួរតែវិលត្រលប់មកមន្ទីរព្យាបាលសុខភាពផ្លូវចិត្តចាស់វិញឬទេ នៅខណៈដែលក្រុមប្រឹក្សានេះធ្វើការវិនិច្ឆ័យ ។

### មូលហេតុនៃសេចក្តីសំរេចចិត្ត

នៅចុងបញ្ចប់នៃការវិនិច្ឆ័យ ក្រុមប្រឹក្សាសំរេចផ្តល់ការសំរាក ពីការព្យាបាលដល់អ្នកជំងឺនីតិក្រមនឹងជំរាបលោកអ្នកពីសេចក្តីសំរេចចិត្តរបស់ខ្លួន និងមូលហេតុនៃការ សំរេចចិត្តនេះ ។ លោកអ្នកនឹងទទួលបានច្បាប់ចំលងមួយស្តីពីការ សំរេចចិត្តនេះ ។ បើសិនលោកអ្នកចង់បានមូលហេតុនៃការសំរេចចិត្តជាលាយល័ក្ខអក្សរលោកអ្នកត្រូវតែសរសេរ សំណើសុំវាពីក្រុមប្រឹក្សាសំរេចផ្តល់ការសំរាកពីការព្យាបាលដល់អ្នកជំងឺនីតិក្រម ហើយក្រុមប្រឹក្សានេះត្រូវតែផ្តល់ជូនលោកអ្នកនូវសេចក្តីបញ្ជាក់មួយស្តីពី មូលហេតុទាំងនោះ នៅក្នុងរយៈពេល១៤ថ្ងៃនៃសំណើរបស់លោកអ្នក ។

## ការបញ្ឈប់មួយរយៈនូវការអនុញ្ញាតឱ្យសំរាកពីការព្យាបាល

ប្រសិនបើនៅខណៈណាមួយប្រធានអ្នកឯកទេសជំងឺរិកលចរិតជឿជាក់ថាសុវត្ថិភាពរបស់លោកអ្នក ឬសុវត្ថិភាពរបស់សាធារណជននឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ នោះការសំរាកពីការព្យាបាលរបស់លោកអ្នកទាំងមូល ឬផ្នែកខ្លះអាចត្រូវបានបញ្ឈប់ ។ បើមានការបញ្ឈប់បែបនេះ លោកអ្នកនឹងត្រូវបានគេប្រាប់ឱ្យដឹង ។

ប្រសិនបើលោកអ្នកមិនទាន់នៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត នោះលោកអ្នកត្រូវតែត្រលប់មកមន្ទីរពេទ្យវិញ ។ លោកអ្នកនឹងទទួលបានសំបុត្របញ្ជាក់ពីការបញ្ឈប់ការសំរាកពីការព្យាបាលពីប្រធានពេទ្យឯកទេសជំងឺរិកលចរិត ។ បើសិនលោកអ្នកនៅតែមិនវិលត្រលប់មកកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្ត វិញទេ ប៉ូលីស ឬអ្នកមានសមត្ថកិច្ចដទៃទៀតអាចចាប់លោកអ្នកនៅពេលណាក៏បាន ។

## ការសំរាកពីការព្យាបាលដោយមានការបន្តពេលថែមទៀត

ការសំរាកពីការព្យាបាលដោយមានការបន្តពេលថែមទៀតអនុញ្ញាតអ្នកជំងឺនីតិក្រម ដែលឋិតនៅក្នុងបទបញ្ជាមើលខុសត្រូវដោយឃាត់ខ្លួន ដើម្បីសំរាកពីការព្យាបាល និងរស់នៅក្នុងសហគមន៍រហូតដល់រយៈពេល១២ខែ ។

ប្រសិនបើលោកអ្នកបានប្រើប្រាស់ដោយជោគជ័យនូវពេលវេលាសំរាកពីការព្យាបាលសំរាកដោយស្នាក់នៅក្នុងបរិវេណកន្លែងព្យាបាល ឬការសំរាកពីការព្យាបាលដោយស្នាក់នៅក្រៅបរិវេណកន្លែងព្យាបាលក្នុងពេលកំណត់ នោះលោកអ្នកប្រហែលជាដល់ពេលអាចដាក់ពាក្យសុំការសំរាកពីការព្យាបាលដោយមានការបន្តពេលថែមទៀត ។បើសិនលោកអ្នកចង់បានការសំរាកពីការព្យាបាលដោយមានការបន្តពេលថែមទៀតលោកអ្នកត្រូវតែដាក់ពាក្យសុំទៅកាន់តុលាការ ដែលបានចេញបទបញ្ជាមើលខុសត្រូវដោយឃាត់ខ្លួន ។ លោកអ្នកនឹងត្រូវការមេធាវីម្នាក់ ដើម្បីជួយលោកអ្នកក្នុងការដាក់ពាក្យសុំនេះ ពីព្រោះដំណើរការដាក់ពាក្យសុំនេះមានលក្ខណៈស្មុគស្មាញ ហើយលោកអ្នកនឹងត្រូវការតំណាងខាងច្បាប់ម្នាក់សំរាប់នៅតុលាការ ។

អង្គការដែលអាចជួយលោកអ្នកបានក្នុងការដាក់ពាក្យសុំ មានរាយឈ្មោះនៅខាងចុងនៃកូនសៀវភៅនេះ ។

លោកអ្នកគួរតែនិយាយជាមួយក្រុមព្យាបាលលោកអ្នក ។ ពួកគេអាចផ្តល់ដំបូន្មាន និងពិភាក្សាពីជំរើសរបស់លោកអ្នកបាន ។ ពេទ្យឯកទេសជំងឺរិកលចរិតរបស់លោកអ្នកនឹងរៀបចំផែនការនៃការសំរាកពីការព្យាបាល សំរាប់ជូនទៅតុលាការ ។ លោកអ្នកអាចចូលរួមក្នុងការធ្វើផែនការនៃការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀតនេះ ហើយចំណង់ចំណូលចិត្តរបស់លោកអ្នកក៏ត្រូវបានគេពិចារណាផងដែរ ។ ផែនការនេះនឹងមានរាប់បញ្ចូលការវាយតំលៃមួយអំពីតំរូវការរបស់លោកអ្នកសំរាប់ការព្យាបាលបន្ត និងការគាំទ្រនៅក្នុងសហគមន៍ និងរាល់មធ្យោបាយប្រសើរបំផុតដែលអាចធ្វើឱ្យលោកអ្នកទទួលបានតំរូវការទាំងនេះ ។ ផែនការនេះក៏បញ្ជាក់ពីការគាំទ្រ ឬមិនគាំទ្រដល់ពាក្យសុំរបស់លោកអ្នកពីសំណាក់ក្រុមព្យាបាលលោកអ្នកផងដែរ ។

ពេទ្យឯកទេសជំងឺរិកលចរិតរបស់លោកអ្នកនឹងផ្ញើជូនតុលាការនូវរបាយការណ៍វេជ្ជសាស្រ្ត និងផែនការសំរាកពីការព្យាបាល របស់លោកអ្នក ។ ច្បាប់ចំឡងនៃឯកសារទាំងនេះក៏ត្រូវបានចែកជូនលោក អ្នក និងតំណាងលោកអ្នកផងដែរ ។ វាជាសិទ្ធិរបស់លោកអ្នកដើម្បីចូលរួមការវិនិច្ឆ័យនៅក្នុងតុលាការ និងដើម្បីមានមេធាវីធ្វើជាតំណាងលោកអ្នក ។ ពេទ្យឯកទេសជំងឺរិកលចរិត និងសមាជិកនៃកុមព្យាបាលរបស់លោកអ្នកនឹងផ្តល់ភស្តុតាងនៅក្នុងតុលាការ ។ តំណាងលោកអ្នក និងលោកអ្នកក៏អាចផ្តល់ភស្តុតាងបានផងដែរ ។

តុលាការអាចផ្តល់ការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត ប្រសិនបើតុលាការពេញចិត្តថា ការផ្តល់នេះនឹងមិនមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់លោកអ្នក ឬសុវត្ថិភាពរបស់សាធារណជនទេនោះ ។ តុលាការនឹងដាក់លក្ខខណ្ឌចំពោះការសំរាកពីការព្យាបាលដោយបន្តពេល ថែមទៀតនេះ ឧទាហរណ៍ ដូចជាទីកន្លែងដែលលោកអ្នកត្រូវរស់នៅ និងទីកន្លែង ព្រមទាំងចំនួននៃការព្យាបាលដែលលោកអ្នកត្រូវទទួលជាទៀងទាត់ ។

ការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀតអាចត្រូវបានផ្តល់ឱ្យរហូតដល់១២ខែ ។ នៅចុងបញ្ចប់នៃពេលសំរាកពីការព្យាបាលដោយមានបន្តពេលថែមទៀត លោកអ្នកអាចដាក់ពាក្យសុំការសំរាកពីការព្យាបាលនេះជាថ្មីទៀតទៅកាន់តុលាការឱ្យបានមុនពេលហួសកំណត់នៃការសំរាកពីការព្យាបាលបច្ចុប្បន្ននេះ ។

បើសិនជាតុលាការបដិសេធពាក្យសុំលោកអ្នក វាជាសិទ្ធិរបស់លោកអ្នកដើម្បីដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់តុលាការឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសំរេចរបស់តុលាការនេះ ។.

### ការបញ្ឈប់ការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត

ប្រសិនបើនៅពេលណាប្រធានពេទ្យឯកទេសជំងឺរិកលចរិតជឿជាក់ថា សុវត្ថិភាពលោកអ្នក ឬសុវត្ថិភាពរបស់សាធារណជននឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ពេលនោះការសំរាកពីការព្យាបាលដោយ បន្តពេលថែមទៀតរបស់លោកអ្នកអាចត្រូវបានបញ្ឈប់មួយរយៈ ។ ប្រធានពេទ្យឯកទេសជំងឺរិកលចរិតនឹងផ្តល់ព័ត៌មានដល់លោកអ្នកជាលាយលក្ខអក្សរពីការបញ្ឈប់នេះ ហើយលោកអ្នកត្រូវវិលត្រឡប់មកកាន់មន្ទីរពេទ្យវិញ ។ បើសិនជាលោកអ្នកមិនវិលត្រឡប់មកវិញទេ ប៉ូលីស ឬជនមានសមត្ថកិច្ចដទៃអាចចាប់លោកអ្នកពេលណាក៏បាន ។

ប្រសិនបើការការបញ្ឈប់នេះមិនត្រូវបានដកចេញវិញក្នុងពេល ៤៨ ម៉ោងទេ ពេលនោះប្រធានពេទ្យឯកទេសជំងឺរិកលចរិតនឹង ដាក់ពាក្យទៅកាន់តុលាការ ដើម្បីសុំឱ្យមានការលប់ចោលការសំរាក ពីការព្យាបាលដោយបន្តពេលថែមទៀតរបស់លោកអ្នក ។ តុលាការត្រូវតែបើកការកាត់ក្តីជាបន្ទាន់ ។ វាជាសិទ្ធិរបស់លោកអ្នកដើម្បីចូលរួមការកាត់ក្តី និងមានមេធាវីជាតំណាងលោកអ្នក ។ ពេទ្យឯកទេសជំងឺរិកលចរិត និងសមាជិកដទៃនៃក្រុមព្យាបាលលោកអ្នកនឹងផ្តល់ភស្តុតាងនៅក្នុងការកាត់ក្តីឯតុលាការ ។ ចំណែកខាងលោកអ្នក គឺលោកអ្នក និងអ្នកគាំទ្រលោកអ្នកក៏អាចផ្តល់ភស្តុតាង និងពន្យល់ពីករណីរបស់លោកអ្នកបានផងដែរ ។

តុលាការនឹងធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួន ហើយនឹងៈ

- ដកចេញការបញ្ឈប់ការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត ។ លោកអ្នកអាចវិលទៅរស់នៅក្នុងសហគមន៍ម្តងទៀតតាមបញ្ជានៃការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត ។ តុលាការអាចផ្លាស់ប្តូរលក្ខខណ្ឌនៃការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀតនេះ ។

  ឬ

- លប់ចោលការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត របស់លោកអ្នក ។ បន្ទាប់មកលោកអ្នកត្រូវតែស្នាក់នៅជាបន្តទៀត នៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្តក្នុងនាមជាអ្នកជំងឺនីតិក្រម ។

## ការចាកចេញពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តដើម្បីទៅរស់នៅក្នុងសហគមន៍វិញ

ផ្នែកនេះនៃកូនសៀវភៅមានព័ត៌មានស្តីពីសិទ្ធិ និងការមានសិទ្ធិទទួលរបស់លោកអ្នកក្រោមច្បាប់ព្រហ្មទណ្ឌ (ពិការភាព និងភាពអន់ថយនៃសុខភាពផ្លូវចិត្ត ដើម្បីធ្វើការកាត់ទោស) ឬច្បាប់ព្រហ្មទណ្ឌនៃរដ្ឋាភិបាលសហព័ន្ធ នៅក្នុងទំនាក់ទំនងនៃការចាកចេញពីមន្ទីរពេទ្យដើម្បីទៅរស់នៅក្នុងសហគមន៍ ។ វិធីដោះលែងលោកអ្នកពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តគឺអាស្រ័យទៅលើវិធីដែលគេបានបញ្ជូនលោកអ្នកមកកាន់មន្ទីរពេទ្យនេះ ។

## បញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក

### ភាពខុសៗគ្នានៃបទបញ្ជាមើលគ្រប់គ្រង

ប្រសិនបើលោកអ្នកបានបញ្ចប់យ៉ាងហោចណាស់ក៏រយៈពេល១២ខែនៃការសំរាកពីការព្យាបាលដោយបន្តពេលថែមទៀត នោះលោកអ្នកអាចដាក់ពាក្យសុំទៅកាន់តុលាការ ដើម្បីប្តូរបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុករបស់លោកអ្នកទៅជា**បទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក** ។ តុលាការអាចបង្កើតបទបញ្ជាមើលគប់គ្រងដោយមិនឃាត់ខ្លួនទុក ប្រសិនបើតុលាការពេញចិត្តថា សុវត្ថិភាពរបស់លោកអ្នកនិងសុវត្ថិភាពរបស់សាធារណជនពុំមានគ្រោះថ្នាក់ធ្ងន់ធ្ងរទេ ។ តុលាការនឹងពិចារណាថាតើលោកអ្នកបានអនុវត្តតាមលក្ខខណ្ឌនៃការសំរាកពីការព្យាបាលដោយមានបន្តពេលថែមទៀតដែរឬទេ ។

ប្រសិនបើតុលាការដោះលែងលោកអ្នកតាមបទបញ្ជាមើលគប់គ្រងដោយមិនឃាត់ខ្លួនទុក នោះលោកអ្នកនឹងអាចទៅរស់នៅក្នុងសហគមន៍ ដោយមានលក្ខខណ្ឌដែលសំរេចដោយតុលាការ ។

ប្រសិនបើតុលាការបដិសេធពាក្យសុំរបស់លោកអ្នក នោះលោកអ្នកមិនអាចដាក់ពាក្យសុំម្តងទៀតទេ រហូតដល់ពាឆ្នាំក្រោយយ៉ាងហោចណាស់ ទើបលោកអ្នកអាចដាក់ពាក្យម្តងទៀតបាន លើកលែងតែតុលាការកំណត់រយៈពេលនេះឱ្យខ្លីជាង ។ លោកអ្នកមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ានឹងសេចក្តីសំរេចរបស់តុលាការទៅកាន់តុលាការឧទ្ធរណ៍ ។

ពេទ្យឯកទេសជំងឺរិកលចរិតរបស់លោកអ្នក លេខាធិការប្រចាំក្រសួងកិច្ចការពលរដ្ឋ ប្រធានរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញានៃរដ្ឋវិចតូរីយ៉ា អាចដាក់ពាក្យសុំផ្លាស់ប្តូរបទបញ្ជារបស់លោកអ្នកបាន ។

### ការពិនិត្យសើរើសំខាន់ៗនៃបទបញ្ជា

នៅពេលដែលតុលាការចេញបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក តុលាការបានកំណត់រយៈពេល ដែលហៅថាអាណត្តិជ្រើសរើស ។ យ៉ាងហោចណាស់ក៏ពាខែដែរមុនពេលចប់អាណត្តិជ្រើសរើស តុលាការត្រូវរៀបចំការពិនិត្យសើរើសំខាន់ៗនៃការរីកចំរើនរបស់លោកអ្នក ។ ការពិនិត្យសើរើនឹងប្រព្រឹត្តឡើងលុះត្រាតែលោកអ្នកនៅតែទទួលបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុកនៅចុងបញ្ចប់ នៃអាណត្តិជ្រើសរើស ។ បើសិនជាតុលាការបានដោះលែងលោកអ្នកពីបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនមុនពេលចប់អាណត្តិ ពេលនោះពុំចាំបាច់មានការពិនិត្យសើរើសំខាន់ណាមួយឡើយ ។

គោលបំណងនៃការពិនិត្យសើរើនេះ គឺដើម្បីសំរេចការដោះលែងលោកអ្នកពីបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុកទៅ **បទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក** ។ តុលាការត្រូវតែដូរបទបញ្ជាទៅជាបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុកជូនលោកអ្នក លុះត្រាតែតុលាការពេញចិត្តថា សុវត្ថិភាព របស់លោកអ្នក និងសុវត្ថិភាពរបស់សាធារណជនពុំមានគ្រោះថ្នាក់ធ្ងន់ធ្ងរទេ ។

ប្រសិនបើតុលាការដោះលែងលោកអ្នកឱ្យឋិតនៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក លោកអ្នកអាចទៅរស់នៅក្នុងសហគមន៍ ដោយមានលក្ខខណ្ឌដែលសំរេចដោយតុលាការ ។

បើសិនតុលាការពុំដោះលែងលោកអ្នកឱ្យឋិតនៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុកទេ នោះលោកអ្នកមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ានឹងសេចក្តីសំរេចរបស់តុលាការទៅកាន់តុលាការឧទ្ធរណ៍ ។

តុលាការនឹងធ្វើការពិនិត្យសើរើករណីលោកអ្នកជាស្វ័យប្រវត្តិជារៀងរាល់ ៥ឆ្នាំម្តង បន្ទាប់ពីការពិនិត្យសើរើសំខាន់លើកទីមួយ នៅក្នុងខណៈដែលលោកអ្នកឋិតនៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក ។

## បទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក

បើសិនលោកអ្នកត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្ត ពីព្រោះតែលោកអ្នកមិនបានអនុវត្តតាមបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក លោកអ្នកត្រូវបានដោះលែងវិញក្នុងរយៈពេល៤៨ម៉ោង លើកលែងតែមានពាក្យសុំដាក់ទៅតុលាការ ដើម្បីកែប្រែបទបញ្ជានេះ ។

បើមានការដាក់ពាក្យសុំ នោះតុលាការត្រូវតែបើកសវនាការជាបន្ទាន់ ។ លោកអ្នកមានសិទ្ធិដើម្បីចូលរួមស្តាប់សវនាការ និងដើម្បីមានមេធាវីជាតំណាងលោកអ្នក ។ ពេទ្យឯកទេសជំងឺវិកលចរិត និងសមាជិកនៃក្រុមព្យាបាលរបស់លោកអ្នកនឹងផ្តល់ភស្តុតាងនៅក្នុងសវនាការ ឧទាហរណ៍ ដូចជាមូលហេតុនៃការមិនគោរពតាមបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក ។ ចំណែកខាងលោកអ្នកគឺលោកអ្នក និងតំណាងរបស់លោកអ្នក ក៏អាចផ្តល់ភស្តុតាង និងពន្យល់ពីករណីរបស់លោកអ្នកបានផងដែរ ។

តុលាការនឹងធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួន ហើយនឹងៈ

- ដោះលែងលោកអ្នកពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តឱ្យ ទៅជាអ្នកជំងឺដែលមានបទបញ្ជាមើលគ្រប់គ្រងដោយមិនឃាត់ខ្លួនទុក ។ តុលាការក៏អាចប្តូរលក្ខខណ្ឌនៃបទបញ្ជា
  ឬ
- **ដាក់លោកអ្នកទៅក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក** ។ បើសិនជាតុលាការបញ្ចូលលោកអ្នកក្នុងបទបញ្ជាមើលគ្រប់គ្រងដោយឃាត់ខ្លួនទុក លោកអ្នកត្រូវតែនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្តក្នុងនាមជាអ្នកជំងឺនីតិក្រម ។

## អ្នកជំងឺនីតិក្រមរបស់រដ្ឋាភិបាលសហព័ន្ធ

### ការដោះលែងចេញពីបទបញ្ជា

បើសិនលោកអ្នកជាអ្នកជំងឺនីតិក្រមរបស់រដ្ឋាភិបាលសហព័ន្ធ លោកអ្នកនឹងត្រូវបានគេដោះលែងពីបទបញ្ជារបស់តុលាការនៅពេលចុងបញ្ចប់នៃរយៈពេលដែលមានចែងនៅក្នុងបទបញ្ជា ហើយលោកអ្នកនឹងពុំមែនជាអ្នកជំងឺនីតិក្រមរបស់រដ្ឋសហព័ន្ធទៀតទេ ។ បន្ទាប់មកលោកអ្នកអាចពិភាក្សាពីការព្យាបាលជាបន្តជាមួយពេទ្យវិកលចរិត ឬអ្នកសំរបសំរួលករណីរបស់លោកអ្នកដែលស្ម័គ្រចិត្ត ។

### បទបញ្ជាដោះលែង

នៅខណៈដែលលោកអ្នកជាអ្នកជំងឺនីតិក្រមរបស់សហព័ន្ធ អគ្គរដ្ឋអាជ្ញាសហព័ន្ធនឹងពិនិត្យសើរើករណីលោកអ្នកជារៀងរាល់៦ខែ ម្តងយ៉ាងហោចណាស់ ដើម្បីពិនិត្យថាតើអាចដោះលែងលោកអ្នកពីមន្ទីរពេទ្យតាម**បទបញ្ជាដោះលែង**បានឬទេ ។

បទបញ្ជាដោះលែងអនុញ្ញាតឱ្យអ្នកជំងឺនីតិក្រមរស់នៅក្នុងសហគមន៍ដោយមានលក្ខខណ្ឌ ដែលលើកឡើងដោយអគ្គរដ្ឋអាជ្ញាសហព័ន្ធ ។

នៅក្នុងការសំរេចបទបញ្ជាដោះលែងនេះ អគ្គរដ្ឋអាជ្ញាត្រូវតែពេញចិត្តថា លោកអ្នកមិនគំរាមកំហែង ឬបង្កគ្រោះថ្នាក់ដល់ ខ្លួនឯងក៏ដូចជាដល់ សហគមន៍ផងដែរ ។

អគ្គរដ្ឋអាជ្ញានឹងទទួលរបាយការណ៍ស្តីអំពីលោកអ្នកពីពេទ្យវិកលចរិត ឬពីអ្នកចិត្តសាស្ត្រ វេជ្ជបណ្ឌិត និងពីនរណាម្នាក់ ដែលអគ្គរដ្ឋអាជ្ញាជ្រើសរើស ។ លោកអ្នក ឬអ្នកណាម្នាក់ដែលជាតំណាងលោកអ្នកអាចផ្ញើព័ត៌មានទៅកានអគ្គរដ្ឋអាជ្ញា ឧទាហរណ៍ ដើម្បីពន្យល់ពីហេតុផលដែលលោកអ្នកគួរតែអនុញ្ញាតឱ្យរស់នៅក្នុងសហគមន៍តាមបទបញ្ជាដោះលែង ។ លោកអ្នកអាចសួរសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ ឬសមាជិកគ្រួសារ មេធាវី ឬភ្ញៀវមកសាកសួរសុខទុក្ខពីសហគមន៍ ដើម្បីឱ្យគេជួយលោកអ្នកពីកិច្ចការនេះ ។

ប្រសិនបើអគ្គរដ្ឋអាជ្ញាចេញបទបញ្ជាដោះលែងរូបលោកអ្នក បទបញ្ជានេះមានសុពលភាពទៅតាមរយៈពេលដែលមានចែងនៅក្នុងបទបញ្ជារបស់តុលាការ ឬរយៈពេល៥ឆ្នាំណាមួយក៏បានកុំឱ្យតែលើសពី៥ឆ្នាំ ។ បទបញ្ជាដោះលែងនេះក៏មានលក្ខខណ្ឌ ដូចជាទីកន្លែងដែលលោកអ្នកត្រូវតែរស់នៅ និងប្រភេទនៃការព្យាបាលដែលលោកអ្នកត្រូវតែទទួល ។

អគ្គរដ្ឋអាជ្ញាអាចលប់ចោលបទបញ្ជាដោះលែងលោកអ្នក បើសិនជាលោកអ្នកមិនអនុវត្តតាមលក្ខខណ្ឌនៃបទបញ្ជាទេ ។ បើករណីនេះកើតមានឡើង លោកអ្នកនឹងត្រូវគេចាប់ខ្លួន ហើយបញ្ជូនទៅកាន់មន្ទីរពេទ្យ ឬពន្ធនាគារ ។

## បណ្តឹង

លោកអ្នកគួរទទួលការប្រព្រឹត្តអំពើមកលើដែលប្រកបដោយកិត្តិយសនិងការគោរព និងត្រូវបានការពារទល់នឹងការប្រព្រឹត្តអំពើមិនគប្បីមកលើ នៅពេលលោកអ្នកទទួលការព្យាបាល និងការថែទាំសំរាប់ស្ថានភាពជំងឺរបស់លោកអ្នក។

បើលោកអ្នកមិនពេញចិត្តអំពីផ្នែកណាមួយនៃការព្យាបាលឬការថែទាំលោកអ្នកទេ លោកអ្នកអាចធ្វើបណ្តឹងបាន។ កន្លែងល្អសំរាប់ចាប់ផ្តើមគឺជាមួយប្រធានករណីលោកអ្នក គិលានុបដ្ឋាកសំខាន់ ឬសមាជិកម្នាក់ទៀតនៃក្រុមព្យាបាល មន្ត្រីទំនាក់ទំនងបណ្តឹង ឬអ្នកពិគ្រោះយោបល់អ្នកប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ វេជ្ជបណ្ឌិតឬគ្រូពេទ្យសរសៃប្រសាទលោកអ្នក ឬនាយកផ្នែកសរសៃប្រសាទនៅឯសេវាសុខភាពផ្លូវចិត្ត។

លោកអ្នកក៏អាចធ្វើបណ្តឹងដោយផ្ទាល់ទៅកាន់ស្នងការសេវាសុខភាព *(Health Services Commissioner)* ផងដែរ តាមទូរស័ព្ទលេខ 8601 5200 ឬប្រធានគ្រូពេទ្យសរសៃប្រសាទ តាមលេខ 1300 767 299 ។

បើលោកអ្នកត្រូវការជំនួយក្នុងការធ្វើបណ្តឹងរបស់លោកអ្នក លោកអ្នកអាចសុំជំនួយពីជនណាមួយដែលលោកអ្នកទុកចិត្ត។ ជននេះប្រហែលជាសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬអ្នកសាកសួរសុខទុក្ខមកពីសហគមន៍។

## ការទាក់ទងសំខាន់ៗ

អង្គការទាំងឡាយដែលលោកអ្នកអាចទាក់ទងសុំជំនួយ និង ទទួលព័ត៌មានបន្ថែមមានរាយឈ្មោះនៅខាងក្រោមនេះ។

- **ក្រុមសំរេចការសំរាកពីការព្យាបាលរបស់អ្នកជំងឺនីតិក្រម** *(Forensic Leave Panel)* គឺជាអង្គការឯករាជ្យមួយ ។ តួនាទីរបស់ក្រុមនេះគឺទទួលពាក្យសុំការ សំរាកពីការព្យាបាលរបស់អ្នកជំងឺនីតិក្រម ។

  50 Lonsdale Street, Melbourne 3000
  លេខទូរស័ព្ទអត់គិតថ្លៃៈ 1800 222 987
  លេខទូរសារៈ 9096 6130

- **អ្នកសាកសួរសុខទុក្ខមកពីសហគមន៍** *(Community visitors)* គឺជាអ្នកដែលអញ្ជើញទៅកាន់សេវាសុខភាពផ្លូវចិត យ៉ាងតិចក៏ម្តងដែរក្នុងមួយខែ ដើម្បីសាកសួរអំពីភាពគ្រប់គ្រាន់នៃសេវានិងគ្រឿងប្រដាប់ប្រដារ សំរាប់ការព្យាបាលនិងការថែទាំអ្នកជំងឺ ស៊ើបអង្កេតបណ្តឹង និងរាយការណ៍អំពីការសាកសួរនិងការស៊ើបអង្កេតរបស់ខ្លួន។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **មណ្ឌលផ្នែកច្បាប់សុខភាពផ្លូវចិត្ត** *(Mental Health Legal Centre)* គឺជាសេវាឯករាជ្យផ្នែកច្បាប់ដែលមានឯកទេសខាងបញ្ហាច្បាប់សុខភាពផ្លូវចិត្ត។ មណ្ឌលនេះអាចរៀបចំធ្វើជាតំណាងជូនលោកអ្នកនៅឯការស្តាប់ក្តីរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញលើសុខភាពផ្លូវចិត្ត ឬផ្តល់ឱវាទអំពីបញ្ហាផ្លូវច្បាប់ផ្សេងទៀត។

  9th Floor, 10–16 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9629 4422
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 555 887

- **ជំនួយផ្នែកច្បាប់រដ្ឋវិចតូរីយ៉ា** *(Victoria Legal Aid)* ផ្តល់ឱវាទផ្នែកច្បាប់ដោយឥតគិតថ្លៃអំពីបញ្ហាផ្សេងៗគ្នាជាច្រើន។ ស្ថាប័ននេះក៏ផ្តល់ជំនួយផ្នែកច្បាប់ផងដែរ បើលោកអ្នកគ្មានប្រាក់ជួលមេធាវីឯកជនបាន ហើយក៏អាចជួយឡើងបកស្រាយផ្នែកច្បាប់នៅឯការប្រជុំរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញផ្នែកសុខភាពផ្លូវចិត្តផងដែរ។

  350 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9269 0234
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 677 402

- **អ្នកគាំទ្រសាធារណៈ** *(Public Advocate)* ជួយផ្តល់ឱវាទនិងគាំទ្រអ្នកដែលមានបណ្តឹងធ្ងន់ធ្ងរអំពីសេវានិងការព្យាបាលសុខភាពផ្លូវចិត្តនិងពិការភាព។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **គណៈកម្មការឱកាសស្មើគ្នានិងសិទ្ធិមនុស្សរដ្ឋវិកតូរីយ៉ា** *(Victorian Equal Opportunity and Human Rights Commission)* ជួយបណ្តាជនក្នុងការដោះស្រាយបណ្តឹងអំពីការប្រកាន់រើសអើង មានមុខងាររជាក់លាក់ដែលទាក់ទងនឹងលក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ ហើយអាចផ្តល់ឱវាទអំពីលក្ខន្តិកៈនេះ។
  សេវាទាំងពួងមានរួមទាំងទូរស័ព្ទសាកសួរ និងសេវាដោះស្រាយបណ្តឹងដោយលាក់ការ ឥតគិតថ្លៃ និងមិនលំអៀង។

  Level 3, 380 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9281 7100
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 13 41 42
  វិបសៃ៖ www.humanrightscommission.vic.gov.au

- **ប្រធានគ្រូពេទ្យសរសៃប្រសាទ** *(Chief Psychiatrist)* គឺជាមន្ត្រីជាន់ខ្ពស់នៃក្រសួងសេវាពលរដ្ឋ ដែលតែងតាំងនៅក្រោមច្បាប់សុខភាពផ្លូវចិត្ត ដោយមានការទទួលខុសត្រូវពិសេសទាក់ទងនឹងអ្នកទទួលសេវាសុខភាពផ្លូវចិត្ត។ ការទទួលខុសត្រូវទាំងនេះមានរួមទាំងអំណាចដើម្បីស៊ើបអង្កេតបណ្តឹងនិងបញ្ហាឯទៀត និងដើម្បីចាត់ឲ្យមានវិធានការចាំបាច់។

  50 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9096 7571
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 767 299

- **ស្នងការសេវាសុខភាព** *(Health Services Commissioner)* គឺជាស្នងការមិនប្រកាន់ខាងណាដែលស៊ើបអង្កេតនិងជួយដោះស្រាយបណ្តឹងដោយអ្នកប្រើប្រាស់ការថែទាំសុខភាព អំពីសេវាសុខភាព ដោយមានរួមទាំងសេវាសុខភាពផ្លូវចិត្ត។ ស្នងការនេះអាចជួយអ្នកជំងឺដើម្បីទទួលព័ត៌មានអំពីសុខភាពរបស់ខ្លួន។

  30th Floor, 570 Bourke Street, Melbourne 3000
  ទូរស័ព្ទ៖ 8601 5200
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 136 066

- **មន្ត្រីស៊ើបអង្កេតបណ្តឹងអំពីមន្ត្រីរដ្ឋការ** *(Ombudsman)* ស៊ើបអង្កេតបណ្តឹងអំពីក្រសួងរបស់រដ្ឋាភិបាល។

  3rd Floor, 459 Collins Street, Melbourne 3000
  ទូរស័ព្ទ៖ 9613 6222
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 806 314

លោកអ្នកក៏អាចសាកសួរប្រធានករណីរបស់លោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាលផងដែរ អំពីអង្គការឯទៀតក្នុងតំបន់ និងក្រុមជំនួយទាំងឡាយ ដែលអាចជួយលោកអ្នកបាន។

## កូនសៀវភៅដែលបោះផ្សាយជាស៊េរី “អំពីសិទ្ធិរបស់លោកអ្នក”៖

- អ្នកជំងឺមិនស្ម័គ្រចិត្ត *(Involuntary patients)*
- បញ្ជាឲ្យទទួលការព្យាបាលដោយមិនស្ម័គ្រចិត្តក្រោមការត្រួតពិនិត្យ *(Restricted involuntary treatment orders)*
- អ្នកជំងឺជាប់ឃុំឃាំង *(Security patients)*
- អ្នកជំងឺនីតិក្រម *(Forensic patients)*
- ការព្យាបាលដោយវិធីឆក់ខ្សែភ្លើង *(Electroconvulsive therapy)*
- ការព្យាបាលចំបងដែលមិនពាក់ព័ន្ធនឹងជំងឺសរសៃប្រសាទ *(Major non-psychiatric treatment)*
- បញ្ជាមើលខុសត្រូវមិននៅក្រោមការឃុំឃាំង *(Non-custodial supervision orders)*

## កូនសៀវភៅផ្សេងទៀតនៅក្នុងស៊េរី “អំពីសិទ្ធិរបស់លោកអ្នក”៖

- អ្នកជំងឺនីតិក្រម (បញ្ជាឃុំខ្លួននិងមើលខុសត្រូវបណ្ដោះអាសន្ន) *(Forensic (remand and interim disposition order) patients)*
- អ្នកជំងឺមិនស្ម័គ្រចិត្តបន្តការព្យាបាលតទៅទៀត (មាត្រាទី 12A – 12D) *(Continuing treatment (section 12A-12D) involuntary patients)*
- បញ្ជាពិនិត្យវាយតម្លៃ និងបញ្ជារោគវិនិច្ឆ័យ ពិនិត្យវាយតម្លៃនិងព្យាបាល *(Assessment orders and diagnosis, assessment and treatment orders)*
- ការវះកាត់ព្យាបាលរោគផ្លូវចិត្ត *(Psychosurgery)*

កូនសៀវភៅទាំងនេះនិងកូនសៀវភៅឯទៀត មាននៅតាមវ៉ិបសៃ www.health.vic.gov.au/mentalhealth ដោយមានអក្សរធំៗ។

មានកូនសៀវភៅមួយចំនួនជាភាសាផ្សេងទៀតផងដែរ។

បោះពុម្ពផ្សាយដោយផ្នែកសុខភាពផ្លូវចិត្តនិងឱសថ (Mental Health and Drugs Division)
ក្រសួងសេវាពលរដ្ឋរបស់រដ្ឋាភិបាលរដ្ឋវិកតូរីយ៉ា ក្រុងមែលប៊ន រដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី។

© សិទ្ធិចំលងនៃរដ្ឋវិចតូរីយ៉ា ក្រសួងសេវាពលរដ្ឋ ឆ្នាំ 2008 ។ .
អាចផលិតឡើងវិញនូវឯកសារនេះ ជាផ្នែកឬទាំងស្រុង បើមានការទទួលស្គាល់សិទ្ធិចំលង។

ខែកញ្ញា 2008 (080519)
អនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ក្រុងមែលប៊ន។

### តើលោកអ្នកត្រូវការកូនសៀវភៅនេះតាមទំរង់មួយទៀតឬទេ?

បើលោកអ្នកត្រូវការកូនសៀវភៅនេះជាទំរង់មួយទៀត លោកអ្នកគួរពិភាក្សាជាមួយ ប្រធានករណីលោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាល។

State Government Victoria
Department of Human Services